# អនុស្សរណៈនៃការយោគយល់គ្នា
# រវាង
# អង្គការសកម្មភាពដើម្បីកុមារ (APLE CAMBODIA)
# និង
# ក្រសួងមហាផ្ទៃ
# ស្តីពី
# ការចូលរួមសកម្មភាពមនុស្សធម៌ក្នុងកិច្ចការពារកុមារ
# នៅព្រះរាជាណាចក្រកម្ពុជា

## បុព្វកថា

- ដោយហេតុថា: **ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា** បានសំដែងនូវបំណងប្រាថ្នាដូចដែលមានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះថា **អង្គការសកម្មភាពដើម្បីកុមារ** បានរួមចំណែកធ្វើការងារមនុស្សធម៌ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈតាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ដោយហេតុថា: **អង្គការសកម្មភាពដើម្បីកុមារ** និង**ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា** ត្រូវសហការគ្នាប្រយុទ្ធប្រឆាំងនឹងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារព្រមទាំងទម្រង់ផ្សេងទៀតនៃអំពើជួញដូរមនុស្ស ។
- ដោយហេតុថា: ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ **អង្គការសកម្មភាពដើម្បីកុមារ** និង**ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា** តាមរយៈការសហការផ្ទាល់ជាមួយ**អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា** មានឆន្ទៈ និងការប្តេជ្ញាចិត្តបន្តកិច្ចសហការលើសកម្មភាព និងគម្រោងកម្មវិធីមនុស្សធម៌ដូចខាងក្រោម៖

### **បន្ទុំបំណង**

ភាគីទាំងពីរត្រូវពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការបង្ការ បង្ក្រាប សង្គ្រោះ ការពារ និងផ្តន្ទាទោសលើអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារគ្រប់ទម្រង់ និងពង្រឹងសមត្ថភាពឆ្លើយតបរបស់ស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសនាយកដ្ឋាន និងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រាជធានី-ខេត្ត។

**ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា** និង**អង្គការសកម្មភាពដើម្បីកុមារ** បានព្រមព្រៀងគ្នាដូចខាងក្រោម៖

# ផ្នែកទី ១

## ភារកិច្ចរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE CAMBODIA) អង្គការសកម្មភាពដើម្បីកុមារត្រូវទទួលខុសត្រូវដូចខាងក្រោម៖

### ប្រការ ១៖ ការប្រមូល និងផ្តល់ព័ត៌មានសម្ងាត់

- **អង្គការសកម្មភាពដើម្បីកុមារ** ប្រមូល និងផ្តល់ព័ត៌មានព្រមទាំងរបាយការណ៍បឋមស្តីពីរាល់សកម្មភាពសង្ស័យពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយផ្ទាល់ ឬតាមរយៈនាយកដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ ដើម្បីធ្វើការស៊ើបអង្កេត ប្រមូលភស្តុតាង និងចាត់ការតាមនីតិវិធីច្បាប់ ។
- **អង្គការសកម្មភាពដើម្បីកុមារ** ធ្វើប្រតិបត្តិការប្រព័ន្ធរាយការណ៍ពិសេសតាមទូរស័ព្ទ២៤ម៉ោង និងតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីទទួល និងវិភាគព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ព្រមទាំងផ្តល់ព័ត៌មានជូននាយកដ្ឋាន និងការិយាល័យជំនាញ ដើម្បីធ្វើការស៊ើបអង្កេត និងចាត់ការតាមនីតិវិធីច្បាប់។
- **អង្គការសកម្មភាពដើម្បីកុមារ** សម្របសម្រួលឲ្យមានកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋាននិងការិយាល័យជំនាញពាក់ព័ន្ធ នគរបាលអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត រួមទាំងអង្គការសកម្មភាពដើម្បីកុមារ ដើម្បីស្វែងរកដំណោះស្រាយរួមគ្នាលើកត្តាប្រឈមនានាក្នុងការអនុវត្តសកម្មភាពដូចមានចែងខាងលើ ។

### ប្រការ ២៖ ការធ្វើអន្តរាគមន៍ និងការសង្គ្រោះ

- **អង្គការសកម្មភាពដើម្បីកុមារ** សហការ សម្របសម្រួល និងផ្តល់ជំនួយគាំទ្រដល់អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋាន និងការិយាល័យជំនាញ ដើម្បីសម្រួលដល់ការសង្គ្រោះជនរងគ្រោះ ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការអនុវត្តនីតិវិធីច្បាប់បន្ត ។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋាន និងការិយាល័យជំនាញ ដើម្បីប៉ាន់ប្រមាណតម្រូវការបឋមរបស់កុមាររងគ្រោះ ផ្តល់សេវាគាំទ្រក្នុងដំណាក់កាលអន្តរាគមន៍វិបត្តិ រួមមាន ការប្រឹក្សាយោបល់ផ្លូវចិត្ត ការផ្តល់កញ្ចប់សុខុមាលភាព ការគាំទ្រឲ្យមានកោសលវិច័យវេជ្ជសាស្ត្រ និងការសម្របសម្រួលឲ្យមានវត្តមានរបស់អាណាព្យាបាល ឬបុគ្គលិកសង្គមកិច្ច ក្នុងពេលសម្ភាសន៍ ។

### ប្រការ ៣៖ ការសម្របសម្រួលក្រោយពេលសង្គ្រោះ

- **អង្គការសកម្មភាពដើម្បីកុមារ** សហការ និងសម្របសម្រួលជាមួយមន្ត្រីនៃនាយកដ្ឋាននិងការិយាល័យជំនាញ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនីតិសម្បទា ក្នុងការប៉ាន់ប្រមាណតម្រូវការរបស់កុមាររងគ្រោះ និងបញ្ជូនពួកគេទៅទទួលសេវាកម្មបន្តរាជធានី-ខេត្ត ។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការ និងសម្របសម្រួលដល់ការជួយគាំទ្រផ្នែកសេវាសង្គម និងសេវាផ្លូវច្បាប់ដល់ជនរងគ្រោះ និងគ្រួសារ ដើម្បីកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្ត ក្នុងដំណើរការចូលរួមស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់។

## ប្រការ ៤៖ ការលើកកម្ពស់ការយល់ដឹង និងពង្រឹងសមត្ថភាព

- **អង្គការសកម្មភាពដើម្បីកុមារ** សហការដឹកនាំ សម្របសម្រួល និងគាំទ្រការរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់មន្ត្រីនគរបាលជាតិនៃនាយកដ្ឋាន និងការិយាល័យជំនាញ លើការអនុវត្តតាមបែបកុមារមេត្រីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការជាមួយមន្ត្រីនគរបាលជាតិដែលត្រូវបានជ្រើសរើសជាគ្រូបង្គោល ដើម្បីតាមដាន និងវាយតម្លៃលើលទ្ធផលនៃការបណ្តុះបណ្តាល ។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការជាមួយមន្ត្រីនគរបាលជាតិដើម្បីជម្រុញ និងលើកកម្ពស់ការអនុវត្តបែបកុមារមេត្រីនៅគ្រប់ដំណាក់កាលនៃនីតិវិធីរឿងក្តីពាក់ព័ន្ធទៅនឹងកុមារ ក្រោយពីទទួលបានវគ្គបណ្តុះបណ្តាល។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ ឬគណៈកម្មាធិការរាជធានីខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដល់សមាជិក សមាជិកានៃ គ.ជ.ប.ជ គ.រ.ប.ជ/គ.ខ.ប.ជ អាជ្ញាធរពាក់ព័ន្ធ សហគមន៍ អង្គការដៃគូ អាណាព្យាបាល យុវជនកុមារ និងផ្នែកឯកជនពាក់ព័ន្ធ។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ ឬ គណៈកម្មាធិការរាជធានី ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ អាជ្ញាធរ ពាក់ព័ន្ធ ដើម្បីរៀបចំ ចងក្រង និងបណ្តុះបណ្តាលបណ្តាញអ្នករាយការណ៍ស្ម័គ្រចិត្តនៅតាមសហគមន៍ងាយរងគ្រោះ ដើម្បីបង្ការ និងការពារកុមារពីហានិភ័យនៃអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។

## ប្រការ ៥៖ ការសិក្សាស្រាវជ្រាវ និងតស៊ូមតិ

- **អង្គការសកម្មភាពដើម្បីកុមារ** ដឹកនាំធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដើម្បីប្រមូលព័ត៌មាន វិភាគ និងចងក្រងជារបាយការណ៍អំពីរបកគំហើញនិងអនុសាសន៍ ដើម្បីប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តគម្រោងកម្មវិធីផ្សព្វផ្សាយនិងតស៊ូមតិសំដៅលើកកម្ពស់ការយល់ដឹងនិងជម្រុញការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារងាយរងគ្រោះ និងកុមាររងគ្រោះ។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការជាមួយ គណៈកម្មាធិការជាតិ គ.ជ.ប.ជ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយរួមគ្នា លើប្រធានបទដែលភាគីទាំងពីរយល់ស្របគ្នា។

## ប្រការ ៦៖ កិច្ចសហការផ្សេងៗទៀត

- **អង្គការសកម្មភាពដើម្បីកុមារ** សហការ និងចូលរួមធ្វើផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងគាំទ្រការអនុវត្តផែនការសកម្មភាពជាតិឲ្យអស់ពីលទ្ធភាពរបស់ខ្លួន។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការចូលរួមយុទ្ធនាការថ្នាក់ជាតិ សំដៅបង្ការ ការពារ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។
- **អង្គការសកម្មភាពដើម្បីកុមារ** សហការចូលរួម និងផ្តល់យោបល់លើសេចក្តីព្រាងបទដ្ឋានគតិយុត្ត និងច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចទៅលើកុមារ។

- **អង្គការសកម្មភាពដើម្បីកុមារ** ចូលរួមគាំទ្រ សម្របសម្រួល និងផ្តល់ធាតុចូល ដល់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្នុងការធ្វើ និងបញ្ជូនរបាយការណ៍អំពីស្ថានភាព និងវឌ្ឍនភាពនៃការការពារកុមារពីអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ ពេស្យាកម្ម រូបភាពអាសអាភាស និងការរំលោភបំពានផ្សេងៗនៅក្នុងប្រទេសកម្ពុជា ទៅអង្គការសហប្រជាជាតិ។

**ប្រការ ៧៖ ការបដិសេធការស្នើសុំ**

- **អង្គការសកម្មភាពដើម្បីកុមារ** នឹងធ្វើការបដិសេធលើការស្នើសុំទាំងឡាយណាប្រសិនបើការស្នើសុំនោះមានលក្ខណៈផ្ទុយពីច្បាប់ជាតិ និងខ្លឹមសារនៃអនុស្សរណៈនៃការយោគយល់គ្នានេះ។
- **អង្គការសកម្មភាពដើម្បីកុមារ** អាចនឹងបដិសេធនូវការស្នើសុំទាំងឡាយណាផងដែរ ប្រសិនបើការស្នើសុំនោះផ្ទុយពីទស្សនៈវិស័យ បេសកកម្ម លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍ផ្ទៃក្នុងផ្សេងៗរបស់អង្គការសកម្មភាពដើម្បីកុមារ ឬ ប្រសិនបើការស្នើសុំនោះលើសពីធនធានរបស់អង្គការសកម្មភាពដើម្បីកុមារ ។ **អង្គការសកម្មភាពដើម្បីកុមារ** នឹងជូនព័ត៌មាន និងមូលហេតុដល់អ្នកស្នើសុំ ក្នុងករណីដែលការស្នើសុំនោះត្រូវបានបដិសេធ ។

## ផ្នែកទី ២
## ភារកិច្ចរបស់ក្រសួងមហាផ្ទៃ
## ក្រសួងមហាផ្ទៃត្រូវទទួលខុសត្រូវដូចខាងក្រោម៖

**ប្រការ ៨៖** ទទួលស្គាល់ថាព័ត៌មាន ដែល**អង្គការសកម្មភាពដើម្បីកុមារ**ប្រមូលបាន ត្រឹមត្រូវតាមនីតិវិធីទាក់ទងនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ផ្តល់ការសហការ និងចាត់វិធានការឆ្លើយតបឲ្យទាន់ពេលវេលា ដើម្បីបង្ការ ការពារ សង្គ្រោះជនរងគ្រោះ បង្ក្រាបបទល្មើស និងកសាងសំណុំរឿងតាមនីតិវិធីច្បាប់ ។

**ប្រការ ៩៖ អគ្គស្នងការដ្ឋាននគរបាលជាតិ** នៃ**ក្រសួងមហាផ្ទៃ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ**ត្រូវដឹកនាំការស៊ើបអង្កេត និងប្រមូលភស្តុតាង ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែល**អង្គការសកម្មភាពដើម្បីកុមារ** បានផ្តល់ព័ត៌មានជូនក្នុងស្មារតីសហការជួយគ្នាទៅវិញទៅមក ។

**ប្រការ ១០៖ អគ្គស្នងការដ្ឋាននគរបាលជាតិ** នៃ**ក្រសួងមហាផ្ទៃ**ទទួលស្គាល់នូវការប្រើប្រាស់ឧបករណ៍បច្ចេកទេសទាំងឡាយរបស់**អង្គការសកម្មភាពដើម្បីកុមារ** ដើម្បីប្រមូលព័ត៌មាន អំពីករណីនៃអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ១១៖ មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** ព្រមទាំង**មន្ត្រីមានសមត្ថកិច្ចផ្សេងទៀត** ត្រូវសហការជាមួយ**អង្គការសកម្មភាពដើម្បីកុមារ** ដើម្បីផ្តល់ព័ត៌មានអោយគ្នាទៅវិញទៅមក និងការរក្សាការសម្ងាត់នៃជំនាញក្នុងគោលបំណងបង្ការ ការពារ និងសង្គ្រោះជនរងគ្រោះពីអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។

**ប្រការ ១២៖ មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** ព្រមទាំង**មន្ត្រីមានសមត្ថកិច្ចផ្សេងទៀត** ត្រូវផ្តល់ការសហការដល់បុគ្គលិករបស់អង្គការសកម្មភាពដើម្បីកុមារ ក្នុងការជួយកំណត់

អត្តសញ្ញាណកុមាររងគ្រោះ ការប៉ាន់ប្រមាណតម្រូវការបឋមរបស់ពួកគេ សម្របសម្រួលឲ្យមានការពិនិត្យកោសលវិច័យវេជ្ជសាស្ត្រ និងលើកកម្ពស់ការចូលរួមរបស់អាណាព្យាបាល ឬបុគ្គលិកសង្គមកិច្ច ក្នុងអំឡុងពេលនៃការសម្ភាសន៍កុមាររងគ្រោះ និងការបញ្ជូនជនរងគ្រោះបន្តទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនីតិសម្បទា ។

**ប្រការ ១៣៖ ក្រសួងមហាផ្ទៃ** និង**អង្គការសកម្មភាពដើម្បីកុមារ** នឹងសហការគ្នារៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជំនាញនៃ**នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** ព្រមទាំង**សមត្ថកិច្ចនគរបាល**ផ្សេងទៀត លើប្រធានបទពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

**ប្រការ ១៤៖ ក្រសួងមហាផ្ទៃ**តាមរយៈ**គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ឬគណៈកម្មាធិការរាជធានីខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់កិច្ចសហការរៀបចំវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដល់សមាជិក សមាជិកានៃ គ.ជ.ប.ជ គ.រ.ប.ជ/គ.ខ.ប.ជ អាជ្ញាធរពាក់ព័ន្ធ សហគមន៍ អង្គការដៃគូ អាណាព្យាបាល យុវជន កុមារ និងផ្នែកឯកជនពាក់ព័ន្ធ ។

**ប្រការ ១៥៖ ក្រសួងមហាផ្ទៃ**តាមរយៈ**គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ឬអាជ្ញាធរពាក់ព័ន្ធ ផ្តល់ការគាំទ្រដល់អង្គការសកម្មភាពដើម្បីកុមារ ក្នុងការរៀបចំ ចងក្រង និងបណ្តុះបណ្តាល បណ្តាញអ្នកវាយការណ៍ស្ម័គ្រចិត្តនៅតាមសហគមន៍ងាយរងគ្រោះ ដើម្បីបង្ការ និងការពារកុមារពីហានិភ័យនៃអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ។

**ប្រការ ១៦៖ ក្រសួងមហាផ្ទៃ**តាមរយៈ**គណៈកម្មាធិការជាតិ គ.ជ.ប.ជ** សហការដឹកនាំធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដើម្បីប្រមូលព័ត៌មាន វិភាគ ចងក្រងជារបាយការណ៍ និងអនុសាសន៍ដើម្បីប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តការផ្សព្វផ្សាយ សំដៅលើកកម្ពស់ការយល់ដឹង និងជម្រុញការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ។

**ប្រការ ១៧៖ ក្រសួងមហាផ្ទៃ**តាមរយៈ**គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ទទួលយកជាតុចូលក្នុងការរៀបចំសេចក្តីព្រាងច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ផែនការយុទ្ធសាស្ត្រ របាយការណ៍អំពីស្ថានភាព និងវឌ្ឍនភាពនៃការការពារសិទ្ធិកុមារ ពីការជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅអង្គការសហប្រជាជាតិជាដើម ។

**ប្រការ ១៨៖ នគរបាលជាតិកម្ពុជា** និង**អជ្ញាធរមានសមត្ថកិច្ច**ផ្សេងទៀតត្រូវសហការធ្វើអន្តរាគមន៍ជាបន្ទាន់នៅពេលដែល**អង្គការសកម្មភាពដើម្បីកុមារ** និងបុគ្គលិករបស់អង្គការត្រូវការកិច្ចសហការបន្ទាន់ក្នុងការសង្គ្រោះ និងជួយគាំទ្រដល់កុមាររងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។

## ផ្នែកទី ៣
## ទំនួលខុសត្រូវរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE)

**ប្រការ ១៩៖ អង្គការសកម្មភាពដើម្បីកុមារ** ត្រូវគោរពអោយបានខ្ជាប់ខ្ជួននូវច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនត្រូវអនុញ្ញាតអោយភ្នាក់ងាររបស់ខ្លួនមានការចូលរួមនូវរាល់សកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជាឡើយ ។

**ប្រការ ២០៖ អង្គការសកម្មភាពដើម្បីកុមារ** ត្រូវប្រតិបត្តិនូវរាល់សកម្មភាព និងអនុវត្តនូវកម្មវិធីមនុស្សធម៌នៅក្នុងប្រទេសកម្ពុជា ដោយផ្អែកទៅតាមធនធានមនុស្ស និងដែនកំណត់នៃមូលនិធិរបស់ខ្លួន ។ ត្រូវធានាថារាល់សកម្មភាពត្រូវបានសុំកិច្ចសហការក្នុងការស៊ើបអង្កេត និងព័ត៌មានឬភស្តុតាងដែលប្រមូលបាន ត្រូវបញ្ជូនទៅអគ្គស្នងការដ្ឋាននគរបាលជាតិ តាមរយៈនាយកដ្ឋាន និងការិយាល័យជំនាញ សម្រាប់ចាត់វិធានការតាមផ្លូវច្បាប់បន្ត ។

**ប្រការ ២១៖ អង្គការសកម្មភាពដើម្បីកុមារ** ប្រកាន់ជំហរអព្យាក្រឹត្យមិនលំអៀង និងចូលរួមតែក្នុងសកម្មភាពមនុស្សធម៌ដែលបានទទួលការអនុញ្ញាតពី**ក្រសួងមហាផ្ទៃ** ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ ។

**ប្រការ ២២៖ អង្គការសកម្មភាពដើម្បីកុមារ** ត្រូវរក្សាការសម្ងាត់នូវព័ត៌មានដែលទទួលបានក្នុងស្មារតីនៃកិច្ចព្រមព្រៀងនេះដោយផ្អែកទៅតាមច្បាប់ជាតិ។ **អង្គការសកម្មភាពដើម្បីកុមារ**ត្រូវធានាដល់ការការពារចំពោះព័ត៌មានសម្ងាត់ពីការចូលមើល ឬស្តាប់ ការកែប្រែ ការបោះពុម្ពផ្សាយ ឬការចែកចាយដែលមិនមានការអនុញ្ញាតដោយយោងទៅតាមច្បាប់ជាតិ ។

## ផ្នែកទី ៤
## អវសានបញ្ញត្តិ

**ប្រការ ២៣៖** រាល់វិវាទដែលកើតឡើងពីការបកស្រាយ ឬការអនុវត្តន៍នៃកិច្ចព្រមព្រៀងអនុស្សរណៈនេះនឹងត្រូវដោះស្រាយតាមរយៈការចរចារដោយសន្តិវិធី និងប្រឹក្សាដោយការយោគយល់គ្នារវាង **ក្រសួងមហាផ្ទៃ** និង**អង្គការសកម្មភាពដើម្បីកុមារ** ។ កិច្ចព្រមព្រៀងនេះនឹងអាចត្រូវបានត្រួតពិនិត្យ ឬធ្វើវិសោធនកម្មឡើងវិញគ្រប់ពេលដោយមានការយល់ព្រមពីភាគីទាំងសងខាងជាលាយលក្ខណ៍អក្សរ។

**ប្រការ ២៤៖** អនុស្សរណៈនៃការយោគយល់គ្នានេះអាចត្រូវបញ្ឈប់ដោយភាគីណាមួយក៏បានគឺបន្ទាប់ពី ៦០ថ្ងៃដែលភាគីនោះបានផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជូនទៅភាគីម្ខាងទៀត ។

**ប្រការ ២៥៖** អនុស្សរណៈនៃការយោគយល់គ្នានេះចូលជាធរមាន និងមានសុពលភាពបន្តរយៈពេលប្រាំ (០៥)ឆ្នាំពីអនុស្សរណៈនៃការយោគយល់គ្នាលើកមុន ហើយអាចនឹងបន្តសាជាថ្មីប្រសិនបើមានការឯកភាព ពីភាគីទាំងពីរ ។

**ប្រការ ២៦៖** អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវបានធ្វើឡើងជាពីរភាសា ភាសាខ្មែរ និងភាសាអង់គ្លេស ។ អត្ថបទទាំងពីរនេះមានតម្លៃស្មើគ្នាតាមផ្លូវច្បាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃពុធ ១ រោច ខែ អាសាឍ ព.ស២៥៦៣
ត្រូវនឹងថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៩

| | |
|---|---|
| **ឧ. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **អង្គការសកម្មភាពដើម្បីកុមារ (APLE CAMBODIA)** |
| **រដ្ឋលេខាធិការ** | |
| **លោកជំទាវ ជូ ប៊ុនអេង** | **លោក សំលៀង សីលា** |

# Memorandum of Understanding
# Between
# Action Pour Les Enfants (APLE Cambodia)
# And
# The Ministry of Interior
# On
# Contribution to Humanitarian Acts in Child Protection in Cambodia

## Preface

- Because of the fact that: The **Ministry of Interior of the Royal Government of Cambodia** has expressed its desire, as stated in the MOU that **Action Pour Les Enfants (APLE Cambodia)** contributes to the humanitarian work for social welfare and public interest through mutual cooperation in the Kingdom of Cambodia.

- Because of the fact that: **Action Pour Les Enfants (APLE Cambodia)** and the **Ministry of Interior of the Royal Government of Cambodia** have to work together to combat child sexual abuse and exploitation and other forms of human trafficking.

- Because of the fact that: To fight against human trafficking and sexual exploitation of children, **Action Pour Les Enfants (APLE Cambodia)** and the **Ministry of Interior of the Royal Government of Cambodia**, in direct and close collaboration with the **General Commissariat of Cambodian National Police**, have the will and commitment to continue the collaboration on the following humanitarian activities and projects:

### Objectives

Both parties shall strengthen cooperation in the prevention, suppression, rescue, protection and prosecution of all forms of human trafficking, child sexual abuse and exploitation, and enhance the responsiveness of government institutions relevant to criminal justice, especially the Department and its Units of the Anti-Human Trafficking and Juvenile Protection, in the capital and provinces.

**The Ministry of Interior of the Royal Government of Cambodia** and **Action Pour Les Enfants (APLE Cambodia)** have agreed as follows:

## SECTION 1

## Action Pour Les Enfants (APLE Cambodia)'s Obligations

Action Pour Les Enfants (APLE Cambodia) is responsible for the following:

**Article 1: Collection and Provision of Confidential Information**

- **Action Pour Les Enfants (APLE Cambodia)** will collect and provide information including a preliminary report on suspicious activities related to human trafficking, child sexual abuse and exploitation to the **General Commissariat of Cambodian National Police** directly or through relevant responsible departments and units for their mandated investigation, evidence gathering and legal action.

- **Action Pour Les Enfants (APLE Cambodia)** will operate a 24/7 telephone and Internet Hotline to receive public reports on suspicious human trafficking, child sexual abuse and exploitation activities, analyze the content and provide information to the responsible departments and units to investigate and take legal action.

- **Action Pour Les Enfants (APLE Cambodia)** will facilitate an exchange of information and meetings between the National Committee for Counter Trafficking (NCCT), the General Commissariat of Cambodian National Police, the relevant responsible departments and units, international law enforcement and other stakeholders, including Action Pour Les Enfants (APLE Cambodia) to identify common solutions to any challenge when implementing the outlined activities in this MOU.

**Article 2: Crisis Intervention and Rescue**

- **Action Pour Les Enfants (APLE Cambodia)** will coordinate and provide appropriate support to the General Commissariat of Cambodian National Police, responsible departments and units during victim rescuing operation, victim identification, and ongoing criminal investigation process.

- **Action Pour Les Enfants (APLE Cambodia)** will cooperate with the General Commissariat of Cambodian National Police, responsible departments and units to assess the immediate need of child victims and provide according support during their crisis intervention, including but not limited to psychological counseling, welfare assistance, forensic and medical care support, and coordination of the presence of the child's legal guardian or a social worker during police interview.

**Article 3: Post Rescue Coordination**

- **Action Pour Les Enfants (APLE Cambodia)** will cooperate and coordinate with officials of the responsible departments and units and the Department of Social Affairs, Veterans and Youth Rehabilitation to assess the need of the affected children and facilitate referrals to appropriate services.

- **Action Pour Les Enfants (APLE Cambodia)** will cooperate and facilitate provision of social and legal support services to victims and their families, needed during their participation in the justice seeking process.

**Article 4: Awareness Raising and Capacity Building**

- **Action Pour Les Enfants (APLE Cambodia)** will co-organise, facilitate and support the Training of Trainer initiative for national police officers of the responsible departments and units in the area of child-centric application within the criminal investigation process involving cases of human trafficking, child sexual abuse and exploitation.

- **Action Pour Les Enfants (APLE Cambodia)** will collaborate with and support the national police officers who are appointed trainers to monitor and evaluate the training outcomes.

- **Action Pour Les Enfants (APLE Cambodia)** will work with the trained national police officers to promote and enhance child-centric application at all stages of the criminal investigation process involving children after their training.

- **Action Pour Les Enfants (APLE Cambodia)** in collaboration with the National Committee for Counter Trafficking (NCCT) and/or Sub-National Committee for Counter Trafficking will organize training, disseminate knowledge and raise awareness on human trafficking and child sexual abuse and exploitation to selected members of NCCT and its subnational committees, local authorities, communities, NGO partners, child parents/guardians, youth, children and the private sector.

- **Action Pour Les Enfants (APLE Cambodia)** in collaboration with the National Committee for Counter Trafficking (NCCT) and/or Sub-National Committee for Counter Trafficking will establish and capacitate network of civil reporters in the selected at-risk communities, enabling their capacity to prevent risks and protect vulnerable children from human trafficking and child sexual abuse and exploitation.

**Article 5: Research and Advocacy**

- **Action Pour Les Enfants (APLE Cambodia)** will conduct research on issues related to human trafficking and child sexual abuse and exploitation to collate and analyze information, produce findings and provide evidence based recommendations for implementing the existing and future knowledge dissemination and advocacy activities, aimed to promote the protection of the rights and best interests of vulnerable and affected children.

- **Action Pour Les Enfants (APLE Cambodia)** will collaborate with the National Committee for Counter Trafficking (NCCT) to conduct and launch joint research and knowledge dissemination on common issues agreed upon by both parties.

**Article 6: Other Cooperation**

- **Action Pour Les Enfants (APLE Cambodia)** will offer other cooperation relevant to, participate in national and sub-national strategic events and support the implementation of the adopted National Plan Action to the best of its capacity.

- **Action Pour Les Enfants (APLE Cambodia)** will participate in national campaigns, aimed to prevent, protect and combat human trafficking and child sexual abuse and exploitation.

- **Action Pour Les Enfants (APLE Cambodia)** will cooperate in the event of and provide technical and/or financial support on drafting and making any

legal instrument that aims to tackle human trafficking and child sexual abuse and exploitation.

- **Action Pour Les Enfants (APLE Cambodia)** will be actively involved in supporting, coordinating and providing inputs to the National Committee for Counter Trafficking (NCCT) in the event of making and submitting periodic reports on the status and progress of child rights implementation and efforts against human trafficking, child sexual abuse/exploitation and other forms of child violence in Cambodia to the United Nations.

**Article 7: Denial of Request**

- **Action Pour Les Enfants (APLE Cambodia)** may reject any request for cooperation, assistance or involvement if it is deemed contradictory to the national law and the content of this MOU.

- **Action Pour Les Enfants (APLE Cambodia)** may also reject any request if it is deemed contradictory to its vision, mission, statute, internal rules and humanitarian principles of the Action Pour Les Enfants (APLE Cambodia) or if the request exceeds the organisation's available resources. **Action Pour Les Enfants (APLE Cambodia)** will seek to provide sufficient information and reasons to the requesting party in the event of such request being denied.

## SECTION 2

## Obligations of the Ministry of Interior

**The Ministry of Interior is responsible for guaranteeing the following:**

**Article 8:** The **Ministry of Interior** shall recognise the information provided by Action Pour Les Enfants (APLE Cambodia) as legitimate and in compliance with the stipulated procedural law relating to human trafficking and child sexual abuse and exploitation, cooperate and respond promptly to the information in order to prevent, protect and rescue victims, suppress crime and build a criminal case for prosecution.

**Article 9:** The **General Commissariat of Cambodian National Police of the Ministry of Interior** and relevant authorities shall conduct investigation in response and collect evidence related to human trafficking and child sexual abuse and exploitation cases which Action Pour Les Enfants (APLE Cambodia) has provided in the spirit of cooperation and mutual assistance.

**Article 10:** The **General Commissariat of Cambodian National Police of the Ministry of Interior** shall recognize the use of technical tools the staff of Action Pour Les Enfants (APLE Cambodia) use to collect information on suspected cases of human trafficking and child sexual abuse exploitation as legitimate and in accordance with the law of the Kingdom of Cambodia.

**Article 11:** The Anti-Human Trafficking and Juvenile Protection Police and other competent authorities shall cooperate with Action Pour Les Enfants (APLE Cambodia) to provide information to each other, ensuring confidentiality of professionalism, for the purpose of preventing, protecting and rescuing victims from the risk of human trafficking, and child sexual abuse and exploitation.

**Article 12:** The Anti-Human Trafficking and Juvenile Protection Police and other competent authorities shall provide support to Action Pour Les Enfants (APLE Cambodia)'s staff in identifying child victims, assessing their primary need, facilitating forensic medical examination and assisting the presence of the child's guardian or a social worker during interview of child victims, and facilitating referrals of child victims to the Department of Social Affairs, Veterans and Youth Rehabilitation or responsible agency.

**Article 13: The Ministry of Interior and Action Pour Les Enfants (APLE Cambodia)** shall co-organize training events for sectarianized police officers of the **Anti-Human Trafficking and Juvenile Protection Department** and its units as well as other authorities on topics relating to human trafficking and child sexual abuse and exploitation.

**Article 14:** The **Ministry of Interior,** through the **National Committee for Counter Trafficking (NCCT)** or its subnational Committee for Counter Trafficking shall co-ordinate training and knowledge dissemination on human trafficking and child sexual abuse and exploitation for members of the Committees at national and subnational levels, relevant authorities, NGO partners, child's parents/guardians, youth, children and the private sector.

**Article 15:** The **Ministry of Interior,** through the **National Committee for Counter Trafficking (NCCT)** or relevant authorities shall provide support to Action Pour Les Enfants (APLE Cambodia) in establishing and capacitating network of civil reporters in the selected at-risk communities in order to prevent and protect children from the risks of human trafficking and child sexual abuse and exploitation.

**Article 16:** The **Ministry of Interior,** through the **National Committee for Counter Trafficking (NCCT)** shall conduct research on topics related to human trafficking and child sexual abuse and exploitation to collate and analyze information, produce findings and evidence based recommendations for implementing knowledge dissemination that aims at raising awareness and promoting the protection of the rights of the child and their best interests.

**Article 17:** The **Ministry of Interior,** through the **National Committee for Counter Trafficking (NCCT)** shall receive inputs for developing draft law and relevant legal instrument, strategic plan and reports on the status and progress of protecting child rights from human trafficking and child sexual abuse and exploitation in the Kingdom of Cambodia to the United Nations.

**Article 18:** The Cambodian National Police and other competent authorities shall cooperate promptly when Action Pour Les Enfants (APLE Cambodia) and its staff request urgent cooperation in rescue of and assistance for child victims of human trafficking and child sexual abuse and exploitation.

## SECTION 3

## Responsibility of Action Pour Les Enfants (APLE Cambodia)

**Article 19: Action Pour Les Enfants (APLE Cambodia)** shall adhere to the laws and regulations of the Kingdom of Cambodia and shall not allow its staff to participate in any other activity that may jeopardize national security, national unity, culture and tradition of the Cambodian people.

**Article 20: Action Pour Les Enfants (APLE Cambodia)** shall execute all activities and implement its humanitarian programs in Cambodia based on the available human resources and the limit of its funds; and shall ensure that cooperation is sought for all

investigative activities and that information/evidence collected is provided to the General Commissariat of Cambodian National Police through the responsible department and/or unit for further legal action.

**Article 21: Action Pour Les Enfants (APLE Cambodia)** shall be neutral and only participate in a humanitarian activity approved by the **Ministry of Interior** for social welfare and public interest.

**Article 22: Action Pour Les Enfants (APLE Cambodia)** shall maintain confidentiality of all information obtained in the spirit of this MOU in accordance with the national law. **Action Pour Les Enfants (APLE Cambodia)** shall ensure the protection of confidential information from unauthorized access or listening to, modification, publication or distribution without permission in accordance with the national law.

## SECTION 4

## Final Provisions

**Article 23:** Any dispute arising out of the interpretation or implementation of this MOU shall be resolved through peaceful negotiation and understanding between the **Ministry of Interior** and **Action Pour Les Enfants (APLE Cambodia)**. This MOU may be reviewed or amended at any point of time with the consent of both parties in writing.

**Article 24:** The Memorandum of Understanding (MOU) may be terminated by either party after 60 days upon which the party gives written notice to the other party.

**Article 25:** This MOU shall be effective and continue the validity from the previous one for five (5) years and may be renewed if both parties agree.

**Article 26:** The MOU is made in two versions, in Khmer and in English. Both versions are of equal legal value.

Made in Phnom Penh, on..........Month...........Buddhist Year 2563

which is on .....12...... of September 2019

**On behalf of the Ministry of Interior,**
**Secretary of State**

**Her Excellency Ms. Chou Bun Eng**

**Action Pour Les Enfants**
**(APLE Cambodia)**

**Mr. Samleang Seila**